ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ..៣៣១៥......អពជ

L202501200600TD3450

ថ្ងៃ ពុធ ១ កើត ខែ មាឃ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង
# ស្តីពី
# ការផ្សព្វផ្សាយសៀវភៅណែនាំស្តីពីស្តង់ដានីតិវិធីប្រតិបត្តិ (SOP) ស្តីពី ពន្ធលើអចលនទ្រព្យ ពន្ធប្រថាប់ត្រា ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងពន្ធលើដីធ្លីមិនបានប្រើប្រាស់

អនុលោមតាមលទ្ធផលនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩ កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ បានសម្រេចឱ្យអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំសៀវភៅណែនាំស្តីពីស្តង់ដានីតិវិធីប្រតិបត្តិ (SOP) ដើម្បីបង្កើតស្តង់ដាររួមឱ្យបានច្បាស់លាស់ ប្រកបដោយតម្លាភាព សម្រាប់ការអនុវត្តរវាងមន្ត្រីពន្ធដារនិងមន្ត្រីពន្ធដារ និងមន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ។ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំសៀវភៅណែនាំស្តីពីស្តង់ដានីតិវិធីប្រតិបត្តិ (SOP) រួចរាល់ ដើម្បីដាក់ឱ្យប្រើប្រាស់និងផ្សព្វផ្សាយជាផ្លូវការក្នុងចំណោមមន្ត្រីពន្ធដារ វិស័យឯកជន អ្នកជាប់ពន្ធ និងសាធារណជន។

ក្នុងន័យនេះ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាអភិបាលក្រុមហ៊ុន អ្នកជាប់ពន្ធ និងសាធារណជនទូទៅមេត្តាជ្រាបជាព័ត៌មាន។ លោក-លោកស្រីអាចទាញយកសៀវភៅណែនាំស្តីពីស្តង់ដានីតិវិធីប្រតិបត្តិ (SOP) តាមរយៈតំណភ្ជាប់ https://www.tax.gov.kh/km/introduction-note ឬ QR Code ដូចខាងក្រោម៖

- សៀវភៅណែនាំស្តីពីពន្ធលើអចលនទ្រព្យ និងបែបបទនិងនីតិវិធីនៃការអនុវត្តពន្ធលើអចលនទ្រព្យ សម្រាប់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ
- សៀវភៅណែនាំស្តីពីពន្ធប្រថាប់ត្រា និងបែបបទនិងនីតិវិធីនៃការអនុវត្តពន្ធប្រថាប់ត្រា សម្រាប់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ
- សៀវភៅណែនាំស្តីពីពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ និងបែបបទនិងនីតិវិធីនៃការអនុវត្តពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ សម្រាប់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ
- សៀវភៅណែនាំស្តីពីពន្ធលើមធ្យោបាយដឹកជញ្ជូន និងបែបបទនិងនីតិវិធីនៃការអនុវត្តពន្ធលើមធ្យោបាយដឹកជញ្ជូន សម្រាប់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ
- សៀវភៅណែនាំស្តីពីពន្ធលើដីធ្លីមិនប្រើប្រាស់ និងបែបបទនិងនីតិវិធីនៃការអនុវត្តពន្ធលើដីធ្លីមិនប្រើប្រាស់ សម្រាប់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ



អគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (+855) 23 886 708 / ទូរសារ: (+855) 23 886 700, E-mail: gdt@tax.gov.kh, Website: www.tax.gov.kh

L202501200600TD3450

ក្នុងករណីលោក-លោកស្រីមានសំណួរ ឬចម្ងល់ផ្សេងៗ អាចអញ្ជើញមកសាកសួរព័ត៌មានដោយផ្ទាល់នៅបញ្ជរផ្តល់សេវាអ្នកជាប់ពន្ធនៅអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្ត-ខណ្ឌ ឬទូរស័ព្ទមកមជ្ឈមណ្ឌលពិគ្រោះយោបល់ (Call Center 1277) ឬចូលជជែកសួរក្នុង GDT Live Chat ដែលអាចទាញយកកម្មវិធីទូរស័ព្ទដៃចេញពី App Store សម្រាប់ iOS ឬ Play Store សម្រាប់ Android។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា សៀវភៅណែនាំស្តីពីស្តង់ដានីតិវិធីប្រតិបត្តិ (SOP) នឹងផ្តល់ជាជំនួយដល់លោក-លោកស្រីក្នុងការស្វែងយល់ដឹងពីនីតិវិធីក្នុងការបង់ពន្ធប្រភេទខាងលើ និងដើម្បីបំពេញកាតព្វកិច្ចសារពើពន្ធឱ្យបានត្រឹមត្រូវ។

**អគ្គនាយកដ្ឋានពន្ធដារ**